

# តើគណបក្សសង្គ្រោះមានគោលជំហរបែបណា ?

មកដល់ថ្ងៃនេះ យើងមិនទាន់មើលឃើញថា តើគណបក្សសង្គ្រោះជាតិ មានគោលជំហរបែបណាលើបញ្ហាផែនទី ដែលរដ្ឋាភិបាល ប្រើសំរាប់បោះបង្គោលព្រំដែន ខ្មែរ/យៀកណាម ក្រៅពី ការប្តេជ្ញាចិត្ត របស់ លោក អ៊ុំ សំអាន ជាសមាជិក និង តំណាងរាស្ត្ររបស់គណបក្ស ស្វែងរកការពិត យ៉ាងក្លៀវក្លា អំពីផែនទី ឆ្នាំ ១៩៦៤ ដែលសម្តេច សីហនុ ផ្ញើជូនដល់ អង្គការសហប្រជាជាតិ និង មហាប្រទេសលោកសេរី មាន អាមេរិកាំង បារាំង និង អង់គ្លេស។

សួរថា តើ លោក អ៊ុំ សំអាន ជា អ្នកនាំពាក្យ ឬ ជាអ្នកដឹកនាំ ក្រុមការងារ របស់ គណបក្ស ក្នុងកិច្ចការព្រំដែន ឬ លោក បន្តធ្វើកិច្ចការនេះ តែម្នាក់ឯង ក្នុងឋានៈលោក ជាខ្មែរ អ្នកស្នេហាជាតិ ក្រោយពី លោក ហ៊ុន សែន បញ្ជាឲចាប់ លោក ហុង សុខហួរ ដាក់ពន្ធនាគារ។ ចំពោះខ្ញុំ ខ្ញុំសុំគោរពដល់ សេចក្តីក្លាហាន របស់ លោក អ៊ុំ សំអាន និងលោក ហុង សុខហួរ មាន **វិកសិតចិត្ត** (ចិត្តរឹង ហើយ រីក) បន្តការតស៊ូតាមផ្លូវ អហឹង្សា និង និត្យានុកូល ស្វែងរកការពិត សំរាប់ ប្រជាជាតិខ្មែរ។

រីឯ លោក សម រង្ស៊ី ពេលដែលមកដល់ស្រុខ្មែរភ្លាម បែរជាថ្លែងថា លោក មកធ្វើឲ ស្ថានភាព នយោបាយ ដែលកំពុងក្តៅ ឲចុះត្រជាក់វិញ ក្នុងគោលជំហរចំហថា អាចនិងធ្វើវិសោធនកម្ម មាត្រាទី២ នៃរដ្ឋធម្មនុញ្ញ បាន បើអាចនាំមកនូវការចំណេញដល់ស្រុកខ្មែរ (Sic) ដែលវាដូចគ្នានឹងគោលជំហរ របស់ លោក ហ៊ុន សែន ដូរ ភូមិខ្មែរ ជាមួយ ភូមិខ្មែរដែលយួន គេថាជា ភូមិរបស់គេ ហើយ ហ៊ុន សែន ថ្លែងថា វិធីនេះ គ្មាន នរណា ចំណេញនរណាខាត អ្វីឡើយ។ រីឯ អ្នកនាពាក្យ គណបក្សសង្គ្រោះជាតិ វិញ ពេលដែល ក្រុមលោកហ៊ុន សែន ចាប់ លោក ហុង សុខហួរ គាត់ថ្លែងថា ការនេះ ជារឿងបុគ្គល ហុង សុខហួរ គ្មានអ្វីទាក់ទងនឹង គណបក្សនោះឡើយ ហើយថ្មីៗនេះទៀត នៅពេល លោក អ៊ុំ សំអាន រកឃើញផែនទី ខ្មែរផ្ញើរក្នុង ១៩៦៤ នៅ សហរដ្ឋអាមេរិក គាត់ថ្លែងដដែលថា ការនេះ ជាកិច្ចការផ្ទាល់របស់ លោក អ៊ុំ សំអាន មិនមែនជា កិច្ចការរបស់គណបក្សនោះទេ។ សួរថា តើគោលជំហរ របស់ គណបក្សសង្គ្រោះជាតិ វាមានបែបណាដែរ ?

បើពិនិត្យមើលទៅ ហាក់បីដូចជាគ្មាន សាមគ្គីភាព រវាង អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ ជាមួយនឹង លោក អ៊ុំ សំអាន ក្នុង កិច្ចការស្វែងរកការពិត លើបញ្ហាផែនទី នោះសោះ នៅពេលដែល ក្រុម ហ៊ុន សែន កំពុងប្រមូលកម្លាំងឡើងវិញដើម្បីធ្វើការ វាយលុកតបវិញ តាមសំដី សម្លុត គ្រប់បែបយ៉ាង ថ្មីៗនេះ របស់ លោក ហោ ណាំហុង, សុខ ទូច និង នាង កុយ ពិសី ។ល។ ហាក់បីក្រុមនេះ រកឃើញ ការពិតជាក់ស្តែងមួយ ដែលអាច

ដោយ ឧប សៅ សង្ហា
២៨ សីហា ២០១៥

ចោទប្រកាន់ជាបទឧក្រិដ្ឋ ដល់អ្នក ដែលនៅតែនិយាយថា ផែនទី រដ្ឋាភិបាល ជាផែនទីក្លែងក្លាយ។

ពាក្យ ក្លែងក្លាយ នេះទៀត លោក សុខ ទូច ចោទប្រកាន់ដល់ លោក អ៊ុំ សំអាន ថាជាការភូតកុហក គ្មានសេចក្តីពិត តែ លោក សុខ ទូច ដែលអួតខ្លួន ថាជា **ពហុមន្តី** (អ្នកមានគំនិតច្រើន, គិតច្រើន, អានច្រើន) លើសអ្នកដទៃ មិនយកមកពិចារណា នូវពាក្យ ក្លែងក្លាយ របស់ លោក អ៊ុំ សំអាន គាត់ប្រើ ក្នុងន័យថា លោក វ៉ា គឹមហុង គាត់ប្រកាសថា ផែនទី រដ្ឋាភិបាល ជាផែនទី យកមក ពី អង្គការសហប្រជាជាតិ តាមពិតវាមិនមែនជាការពិត។

នាង កុយ ពិសី វិញ នាងថ្លែងថា ផែនទី ដែល លោក អ៊ុំ សំអាន រកឃើញថ្មីៗនេះ នៅសហរដ្ឋអាមេរិក ថា រដ្ឋាភិបាល មានយូរមកហើយ តើសំដីនេះ នាងបានពិគ្រោះជាមួយ លោក សុខ ទូច រួចហើយឬនៅ មុននឹងប្រកាសជាសាធារណ: បែបនេះ ព្រោះថា លោក សុខ ទូច គាត់តែងតែនិយាយថា គាត់ធ្វើកិច្ចការព្រំដែននេះ ដោយតម្លាភាព គ្មានអ្វីលាក់បាំងនោះឡើយ។ ចុះហេតុអ្វី ក៏ចេញថា រដ្ឋាភិបាល មានផែនទី លោក អ៊ុំ សំអានទើបរកឃើញនេះដែរ ដែលក្រុមខ្លួនមិនដែលនិយាយសោះ។ រឿងនេះគ្មានអ្វីពិបាកយល់នោះឡើយ មនុស្សនិយាយភរកុហក តែងតែផ្លាត់និយាយបែបនេះឯង ព្រោះ មនុស្សបែបនេះ គ្មាន សតិ អាចចាំ នូវអ្វីដែលខ្លួនបាននិយាយ រួចមកហើយនោះឡើយ ដែលខ្មែរយើងតែងតែនិយាយថា «មនុស្សមានខួរក្បាលបង្កង»។

លោក សុខ ទូច ស្នើរសុំផែនទី ដែល លោក អ៊ុំ សំអាន ទើបតែរកឃើញ។ ការស្នើរនេះវាមិនផ្ទុយពីសំដី នាង កុយ ពិសី នោះទេ ? ចំពោះខ្ញុំ មិនត្រូវប្រគល់ផែនទីឲលោក សុខ ទូច ទេ ព្រោះគាត់គ្មាន ជំនាញការ និង ជនមានគុណសម្បត្តិ ជា អាជ្ញាកណ្តាល ធ្វើការវិនិច្ឆ័យបាននោះឡើយ។ សុខ ទូច តែងតាំង ដោយ ហ៊ុន សែន ដូច្នេះ សុខ ទូច ត្រូវតែការពារប្រយោជន៍ ហ៊ុន សែន ហើយ ខ្មែរដឹងច្បាស់ហើយ ថា ប្រយោជន៍ ហ៊ុន សែន មិនមែន ជាប្រយោជន៍ជាតិខ្មែរ នោះទេ។ ត្រូវរក រូបមន្តថ្មី ក្នុងការ ផ្ទៀងផ្ទាត់ ផែនទី រដ្ឋាភិបាល ជាមួយនឹង ផែនទី ដែល លោក អ៊ុំ សំអាន ទើបតែរកឃើញ ដែលនាង កុយ ពិសី ថ្លែងថា រដ្ឋាភិបាលមានយូរហើយ៕

ដោយ ឧប សៅ សង្ហា
២៨ សីហា ២០១៥